| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | ភាសាខ្មែរ |
| **ប្រធានបទ** | ការអភិវឌ្ឍផ្នែកភាសា<br>(ការស្តាប់មតិអ្នកដំទៃ បង្ហាញបំណិនសន្ទនា ) |
| **ចំណងជើងមេរៀន** | ល្បែងអានសៀវភៅរឿង តើអ្នកពូកែអី? |
| **កម្រិត** | ទាប ៣០នាទី |
| **គោលបំណង** | -កុមារយល់ពីអ្វីដែលគេបាននិយាយ និងមានសមត្ថភាពធ្វើតាមការណែនាំងាយៗ ( ស្តាប់យោបល់អ្នកដំទៃ)ក្នុងភាសាជាតិ ឬភាសាកំណើត។<br>-កុមារប្រើពាក្យសន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្របទៅតាមវ័យ។ |
| **បំណិនសម្បទា** | កុមារអាចឆ្លើយសំណួរអំពីរឿងបាន។ |
| **ចរិយាសម្បទា** | ផ្តោតការយកចិត្តទុកដាក់ទៅលើសាច់រឿង។ |
| **គ្រូបង្រៀន** (ផលិតសម្ភារឧបទេស) | អានសៀវភៅរឿងសៀវភៅតើអ្នកពូកែអី?<br>ជាមុន ដើម្បីឱ្យដឹងសាច់រឿង។ |
| **កុមារ** | កុមារចូលរួមស្តាប់ការអានរឿង។ |
| **ការរៀបចំ** | រៀបចំសំណួរដែលត្រូវសួរកុមារ។<br>គ្រូបង្រៀនអានសៀវភៅតើអ្នកពូកែអី? |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|
| ១. បង្ហាញសៀវភៅរឿងទៅកាន់កុមារទាំងអស់គ្នា។<br>២. ឱ្យពួកគេថាតាមពាក្យថា "សៀវភៅ" ។<br>៣. និយាយពីរបៀបនៃការកាន់ និងថែរក្សាសៀវភៅ។<br>៤. មើលគ្រប់មុខនៃសៀវភៅ។<br>៥. ពន្យល់ចំណងជើងជាអ្វី។<br>៦. ឱ្យកុមារទាំងអស់ថាតាមពាក្យ "ចំណងជើង" ។<br>៧. អានសៀវភៅរឿងទាំងមូលដោយបង្ហាញរូបភាពក្នុងទំព័រនីមួយៗយឺតៗ ។<br>៨. បង្ហាញរូបភាពម្តងទៀត និងពិភាក្សាថារូបភាពទាំងនោះបង្ហាញពីអ្វី។<br>៩. សួរសំណួរដែលអ្នកបានត្រៀមទៅកាន់កុមារទាំងអស់។<br>១០. ឆ្លើយសំណួរផ្សេងៗដែលកុមារមាន។ | ឧទាហរណ៍ខ្លះសម្រាប់សំណួរ៖<br>១. តើអ្នកចាំថាមានសត្វអ្វីនៅជាមួយជេក ដែរឬទេ?<br>២. តើសត្វនោះមានឈ្មោះអ្វី?<br>៣. តើសត្វនោះមកពីប្រទេសណា?<br>៤. តើសត្វនោះមានសម្បុរអ្វី?<br>៥. តើសត្វនោះស្លៀកពាក់សម្លៀកបំពាក់បែបណា? | ១. ចូរស្តាប់រឿងដោយយកចិត្តទុកដាក់។<br>២. ចូរផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចលម្អិតនៃរូបភាព។<br>៣. ចូរឆ្លើយសំណួរដែលអ្នកគ្រូ/លោកគ្រូសួរ។<br>៤.ចូរក្លាហាន ហ៊ានសួរសំណួរទៅកាន់អ្នកគ្រូ/លោកគ្រូ ប្រសិនបើអ្នកមិនយល់។ |